# ការធ្វើតេស្ត ផ្ទះរបស់ខ្ញុំដើម្បីរកមើល សារធាតុសំណ








## មានវិធីមួយចំនួន ដែលអាចប្រើដើម្បីធ្វើតេស្តផ្ទះរបស់អ្នករកមើលថា មានសារធាតុសំណដែរឬទេ ។

វិធីខ្លះសម្រាប់ធ្វើតេស្តរកសារធាតុសំណ មានភាពល្អប្រសើរជាងវិធីខ្លះទៀត ។ វិធីនីមួយៗ មានតម្លៃ និងរយៈពេលខុសៗគ្នា ហើយកម្រិតនៃភាពត្រឹមត្រូវក៏ខុសគ្នាដែរ ។ កូនក្មេងភាគច្រើន ពុលសារធាតុសំណ ចេញពីធូលីសំណ ដែលបង្ករដោយថ្នាំលាបផ្ទះ ។ នេះហើយ ជាសារៈសំខាន់ ក្នុងការធ្វើតេស្តថ្នាំលាបផ្ទះ និងធូលីដីក្នុងផ្ទះ រកមើលសារធាតុសំណ នៅក្នុងផ្ទះ ដែលបានកសាងមុនឆ្នាំ 1950 ។

### ថ្នាំលាបផ្ទះ និងធូលីដី

មានវិធីមួយចំនួន ដើម្បីធ្វើតេស្តថ្នាំលាបផ្ទះ និងធូលីដីក្នុងផ្ទះ រកមើលសារធាតុសំណ ។ វិធីសាស្ត្រនីមួយៗ សុទ្ធតែមានចំណុចល្អ និងអាក្រក់របស់វា ។

### កញ្ចប់សម្រាប់ធ្វើតេស្តសារធាតុសំណក្នុងផ្ទះ

អ្នកអាចប្រើកញ្ចប់សម្រាប់ធ្វើតេស្តសារធាតុសំណក្នុងផ្ទះ ដែលអ្នកទិញពីហាងលក់គ្រឿងសំណង់ ដើម្បីរកមើលសារធាតុសំណក្នុងផ្ទះរបស់អ្នក ។ ការធ្វើតេស្តទាំងអស់នេះ គឺគ្រាន់តែអាចប្រាប់អ្នកបានថា តើមានសារធាតុសំណតាមបរិវេណនានាតែប៉ុណ្ណោះ ។ វិធីទាំងអស់នេះ មិនអាចប្រាប់អ្នកបានទេថា តើមានថ្នាំលាបដែលមានសារធាតុសំណ **ស្ថិតនៅពីក្រោម**ស្រទាប់ថ្នាំលាបដែលមិនមានលាយសារធាតុសំណ ។ វិធីសាស្ត្រទាំងអស់នេះ មានប្រយោជន៍បំផុតសម្រាប់តេស្តថ្នាំលាបលើអ្វីៗដែលធ្វើពីឈើ ដែលវាប្រេះ ឬខូចខាតទៅហើយ ។ កញ្ចប់សម្រាប់ធ្វើតេស្តសារធាតុសំណក្នុងផ្ទះ មិនថ្លៃទេ ។

### ជូតសំអាតធូលីសំណ

ធូលីសំណ គឺជាប្រភពសាមញ្ញបំផុតដែលធ្វើឲ្យកុមារនៅរដ្ឋមេន ពុលសារធាតុសំណ ។ អ្នកអាចធ្វើតេស្តរកមើលសារធាតុសំណនៅតាមកម្រាល និងបន្ទះទម្របង្អួច ក្នុងផ្ទះរបស់អ្នកដោយខ្លួនឯង ឬជួលអ្នកឯកទេសមកធ្វើតេស្តឲ្យអ្នក ។ អ្នកអាចទទួលបានកញ្ចប់សម្រាប់ធ្វើតេស្តធូលីសំណ ពីមន្ទីរពិសោធន៍របស់រដ្ឋមេន តាមទូរស័ព្ទលេខ 287-8014 ។ ការដែលអ្នកដឹងថា នៅលើបរិវេណបន្ទះទម្របង្អួច ឬកម្រាលផ្ទះអ្នក មានកំណកធូលីសំណ អាចជួយអ្នកក្នុងការធ្វើឲ្យកូនរបស់អ្នក គេចផុតពីការពុលសារធាតុសំណ ។

### អ្នកឯកទេសសារធាតុសំណ

អ្នកអាចជួលអ្នកឯកទេសសារធាតុសំណឲ្យមកធ្វើតេស្តផ្ទះរបស់អ្នករកមើលសារធាតុសំណ ។ ពួកគេមានឧបករណ៍ សម្រាប់ស្ទង់រកមើលសារធាតុសំណក្នុងថ្នាំលាបផ្ទះ បើទោះបីជាថ្នាំនោះ វាស្ថិតនៅស្រទាប់ក្រោមនៃថ្នាំដែលមិនមានសារធាតុសំណ ដែលលាបថ្មីក៏ដោយ ។ ពួកគេ អាចធ្វើតេស្តផ្ទះរបស់អ្នកទាំងមូល ឬតេស្តក្នុងបន្ទប់ណាមួយក៏បាន ។ បើទោះបីជា ជម្រើសមួយនេះ វាមានតម្លៃថ្លៃខ្លាំងក៏ដោយ ក៏លទ្ធផលទទួលបាន មានភាពត្រឹមត្រូវបំផុត សម្រាប់អ្នក ផងដែរ ។ អ្នកអាចទទួលបានបញ្ជីឈ្មោះអ្នកធ្វើតេស្តរកមើលសារធាតុសំណក្នុងផ្ទះ តាមទូរស័ព្ទលេខ 287-2651 ឬរកមើលព័ត៌មាននេះ ក្នុងផ្នែកនិយាយអំពីម្ចាស់ផ្ទះ នៅក្នុងវិបសៃត៍ maine.gov/healthyhomes ។

### ដី ឬទឹក

ជាទូទៅ ដី និងទឹក នៅរដ្ឋមេន មិនមែនជាប្រភពបង្ករឲ្យកើតការពុលសារធាតុសំណឡើយ ។ តែយើងក៏ត្រូវគិតអំពីពេលវេលា ដែលគួរធ្វើតេស្តដី និងទឹក ដើម្បីរកមើលសារធាតុសំណដែរ ។

### ការធ្វើតេស្តដីរបស់អ្នក រកមើលសារធាតុសំណ

បើអ្នកមានផ្ទះ ដែលបានសាងសង់នៅមុនឆ្នាំ 1950 អ្នកត្រូវគិតថា វាអាចមានសារធាតុសំណនៅក្នុងដីនៅក្បែរខាងផ្ទះរបស់អ្នក ។ ហាមដាំដំណាំ ឬឲ្យកូនរបស់អ្នកលេងលើដី ក្នុងចម្ងាយ 10 ហ្វីតពីផ្ទះ ។

បើកូនរបស់អ្នកលេងដី ឬបើពួកគេតែងយកដីដាក់ចូលមាត់ សូមធ្វើតេស្តដីនោះ ដើម្បីរកមើលសារធាតុសំណ ។ អ្នកអាចទទួលបានកញ្ចប់សម្រាប់ធ្វើតេស្តដីរកមើលសារធាតុសំណពីមន្ទីរពិសោធន៍របស់រដ្ឋមេន តាមទូរស័ព្ទលេខ 287-8014 ឬពីសកលវិទ្យាល័យមេន តាមទូរស័ព្ទបញ្ជូនបន្តលេខ 581-3591 ។

### ការធ្វើតេស្តទឹករបស់អ្នករកមើលសារធាតុសំណ

សារធាតុសំណនៅក្នុងទឹក គឺវាចេញមកពីទុយ៉ូទឹក ។ បើទឹកនៅក្នុងផ្ទះរបស់អ្នកជាទឹកដែលអាចកាត់វត្ថុផ្សេងបាន គឺវាអាចធ្វើឲ្យសារធាតុសំណនៃទឹកអន្ទ្យមុខតំណនៅក្នុងទុយ៉ូទង់ដែងរលាយចូលក្នុងទឹកបាន ។

បើអ្នកប្រើទឹកម៉ាស៊ី របស់រដ្ឋាករទឹកសាធារណៈ សូមហៅទូរស័ព្ទជួបជាមួយក្រុមហ៊ុនរដ្ឋាករទឹករបស់អ្នក ដើម្បីសួរនាំអំពីលទ្ធផលការធ្វើតេស្តចុងក្រោយរបស់ពួកគេ ឬសួរនាំពីរបៀបធ្វើតេស្តរកមើលសារធាតុសំណក្នុងទឹកនៅផ្ទះរបស់អ្នក ។

បើអ្នកប្រើទឹកអណ្តូងឯកជន អ្នកអាចធ្វើតេស្តទឹកនោះរកមើលវត្តមានសារធាតុសំណ និងរកមើលបញ្ហាផ្សេងទៀតផងដែរ ។ តេស្តទឹកអណ្តូងរបស់អ្នក រកមើលសារធាតុសំណ បើអ្នកមានកូនតូច ឬបើអ្នកសង្កេតឃើញស្នាមប្រលាក់ពណ៌បៃតង ត្រង់បរិវេណដែលទឹកស្រក់ (ដូចជាអាងងូតទឹក ឬធុងលាងចាន) ។ រៀនពីរបៀបធ្វើតេស្តទឹកអណ្តូងរបស់អ្នក នៅឯ ៖ wellwater. maine.gov ឬដោយការហៅទូរស័ព្ទទៅលេខ 866-292-3474 (លេខហៅមិនអស់ប្រាក់នៅរដ្ឋមេន) ។

### ការពារគ្រួសាររបស់អ្នក ។

- សូមឆែកមើលព័ត៌មានក្នុងវិបសៃត៍នេះ ៖ maine.gov/healthyhomes
- ហៅទូរស័ព្ទទៅលេខនេះ ដើម្បីសុំដំបូន្មាន ៖ **866-292-3474 • អ្នកប្រើ TTY សូមហៅទៅលេខ ៖ លេខបន្តរបស់រដ្ឋមេន 711**